# សុន្ទរកថា
# សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
# នៃព្រះរាជាណាចក្រកម្ពុជា

ក្នុងពិធីបិទសន្និសីទជាតិស្តីពី
កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការៈ “មេរៀនបទពិសោធន៍ បញ្ហាប្រឈម
និងចក្ខុវិស័យទៅអនាគត ”

## ថ្ងៃ៧-៨កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១ត្រូវនឹងថ្ងៃទី២១-២២ ខែកុម្ភៈ ឆ្នាំ២០១៨
## រាជធានីភ្នំពេញមជ្ឈមណ្ឌលសន្និបាតកោះពេជ្រ

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ភ្ញៀវកិត្តិយស និងសមាជិក សមាជិកានៃអង្គសន្និសីទជាតិទាំងមូលជាទីមេត្រី**!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដោយបានមកចូលរួមក្នុងពិធីបិទសន្និសីទជាតិស្តីពីការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលបានប្រព្រឹត្តទៅអស់រយៈពេលជិត២ថ្ងៃកន្លងមក ក្រោមការរៀបចំ និងសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលហៅកាត់ថា គ.ជ.អ.ប។

ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមវាយតម្លៃខ្ពស់ និងសូមសម្តែងនូវការកោតសរសើរដោយស្មោះចំពោះ គ.ជ.អ.ប ដែលបានបំពេញតួនាទី និងការទទួលខុសត្រូវដែលរាជរដ្ឋាភិបាលបានប្រគល់ឱ្យក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការជាទូទៅនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រកបដោយជោគជ័យ និងសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើន ដូចដែលបានរៀបរាប់នៅក្នុងរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងរបាយការណ៍សង្ខេបរបស់**សម្តេចក្រឡាហោម សខេង**នាពេលអំបាញ់មិញនេះ។ ព្រមជាមួយនេះ ខ្ញុំសូមសម្តែងការកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិនានាដែលបានខិតខំប្រឹងប្រែងចូលរួមអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ និងកំណែទម្រង់សំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាល។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំក៏សូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការជួយគាំទ្រទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកបច្ចេកទេស ព្រមទាំងកិច្ចសហការរបស់ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលនានានៅក្នុងការអនុវត្តគោលនយោបាយកំណែទម្រង់ដ៏មានសារៈសំខាន់នេះតាំងពីដំណាក់កាលដំបូងរហូតមកដល់បច្ចុប្បន្ន។

**សម្តេច ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!**

សន្និសីទជាតិដែលបានរៀបចំឡើងនាពេលនេះសមស្របនឹងកាលៈទេសៈដែលកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានឈានដល់ដំណាក់កាលកាន់តែស៊ីជម្រៅ និងឈានដល់របត់ផ្លូវមួយដែលមានភាពកាន់តែស្មុគស្មាញ និងសាំញ៉ាំទាំងក្នុងកិច្ចការនយោបាយ និងបច្ចេកទេសក្នុងក្របខ័ណ្ឌនៃការបែងចែកមុខងារ និងការទទួលខុសត្រូវឱ្យបានច្បាស់លាស់រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ រវាងថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងការរៀបចំនូវបែបផែននៃការគ្រប់គ្រងផ្សេងៗគ្នារវាងតំបន់ទីក្រុង ទីប្រជុំជនដែលកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស និងតំបន់ជនបទដើម្បីធានាដល់ការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះគំនិត និងយោបល់របស់វាគ្មិនទាំងឡាយដែលបានចូលរួមធ្វើការវិភាគ វាយតម្លៃ និងផ្តល់យោបល់នៅក្នុងសន្និសីទជាតិនេះទៅលើបញ្ហាប្រឈម និងដំណោះស្រាយនានា ស្របពេលដែលរាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការលើកកម្ពស់នូវភាពជាអ្នកដឹកនាំ និងភាពជាម្ចាស់ក្នុងការបន្តជំរុញកិច្ចដំណើរការកំណែទម្រង់នេះឱ្យកាន់តែស៊ីជម្រៅផ្អែកលើបរិការណ៍ថ្មីៗនៃនយោបាយសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជា។

ខ្ញុំសូមឆ្លៀតឱកាសរំឭកជាថ្មីឡើងវិញថា យើងទាំងអស់គ្នាត្រូវតែទទួលស្គាល់ថាសន្តិភាព និងស្ថេរភាពនយោបាយនៅកម្ពុជាគឺជាសមិទ្ធផលដ៏សំខាន់បំផុតរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។ បើគ្មានសន្តិភាព និងស្ថេរភាពនយោបាយ យើងក៏ពុំអាចមានការអភិវឌ្ឍ និងបន្តពង្រីកសមិទ្ធផលដែលយើងខិតខំសម្រេចបាននារយៈពេលកន្លងមកនោះឡើយ។ ជាការពិតណាស់ គឺដោយសារតែសន្តិភាព ស្ថេរភាពនយោបាយកំណើនសេដ្ឋកិច្ច និងការរីកចម្រើននៃវិស័យសង្គមកិច្ចក្នុងរយៈពេលជាច្រើនឆ្នាំជាបន្តបន្ទាប់កន្លងមកបានធ្វើឱ្យកម្ពុជាកាន់តែមានទំនុកចិត្ត និងត្រៀមខ្លួនយ៉ាងច្បាស់លាស់ក្នុងការបោះជំហានទៅមុខឆ្ពោះទៅរកអនាគតដ៏រុងរឿងមួយប្រកបដោយសុទិដ្ឋិនិយម។ ជារួមរាល់ជម្រើសនានានៅក្នុងកិច្ចការនយោបាយដែលយើងបានប្រកាន់យកនារយៈពេលកន្លងមក និងសម្រាប់ដំណាក់កាលបច្ចុប្បន្ននេះបានឆ្លុះបញ្ចាំងឱ្យឃើញពីការក្តាប់ជាប់នូវកាលានុវត្តភាព និងការធ្វើសេចក្តីសម្រេចចិត្តក្នុងការប្រកាន់យកជំហាននានា ដោយផ្អែកលើហេតុផលសមស្របដែលយើងធ្លាប់ទទួលបានពីមេរៀនបទពិសោធន៍នៃប្រវត្តិសាស្ត្ររបស់យើង និងដែលយើងអាចទុកចិត្តបានសម្រាប់ជោគវាសនាអនាគតរបស់ប្រទេសជាតិ និងប្រជាជនយើងផងដែរ។

យោងតាមចក្ខុវិស័យដែលពាក់ព័ន្ធនឹងការលើកកម្ពស់អភិបាលកិច្ចល្អនៃស្ថាប័នសាធារណៈគ្រប់ថ្នាក់ រាជរដ្ឋាភិបាលបានចាប់ផ្តើមដាក់ចេញ និងអនុវត្តនូវគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលជាការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលតាមបែបប្រជាធិបតេយ្យចាប់តាំងពីប្រទេសយើងទទួលបាននូវសន្តិភាព ឯកភាពជាតិ ឯកភាពទឹកដីយ៉ាងពេញលេញទូទាំងប្រទេសតាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះនាចុងទស្សវត្សឆ្នាំ៩០មកម្លេះ។ បន្ទាប់ពីទទួលបាននូវសន្តិភាព ឯកភាពជាតិភ្លាម ដោយក្តាប់ជាប់នូវកាលានុវត្តភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមសិក្សា

ពិចារណាអំពីជម្រើសនានាក្នុងការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិ ដោយចាប់ផ្ដើមពីរដ្ឋបាលថ្នាក់ឃុំ សង្កាត់ដែលជារដ្ឋបាលនៅជាប់ផ្ទាល់ជាមួយប្រជាពលរដ្ឋ។ ចុងក្រោយ យើងបានស្វះស្វែងរកការស្រុះស្រួលឯកភាពគ្នាខាងនយោបាយ ដោយរៀបចំឱ្យមានការបោះឆ្នោតដោយផ្ទាល់ដើម្បី ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរី ពហុបក្ស និងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់។ ដោយមានការប្ដេជ្ញាចិត្តយ៉ាងមុតមាំរបស់រាជរដ្ឋាភិបាលកម្ពុជា ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទូទាំងប្រទេសជាលើកដំបូង បានប្រព្រឹត្តទៅប្រកបដោយជោគជ័យជាប្រវត្តិសាស្ត្រនាខែកុម្ភៈ ឆ្នាំ២០០២ ក្នុងនោះរួមទាំងឃុំសង្កាត់ដែលបានបង្កើតឡើងក្នុងតំបន់ដែលទើបបានធ្វើសមាហរណកម្មពីបងប្អូនអតីតខ្មែរក្រហមផងដែរ។ ដូច្នេះ ការបោះឆ្នោតនៅថ្នាក់ឃុំ សង្កាត់នៅពេលនោះមិនគ្រាន់តែជាការពង្រឹងលទ្ធិប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែការបោះឆ្នោតនេះក៏ជាកិច្ចដំណើរការមួយក្នុងការពង្រឹងការផ្សះផ្សារ បង្រួបបង្រួមជាតិ ក្នុងចំណោមកម្លាំងនយោបាយនានាក្នុងក្របខ័ណ្ឌជាតិទាំងមូល ដើម្បីចូលរួមចំណែកដល់ការពង្រឹងសន្តិភាព ស្ថេរភាពនយោបាយនៅកម្ពុជាចាប់ពីពេលនោះមក។ ក្រុមប្រឹក្សាដែលជាប់ឆ្នោតទាំងនេះបានដើរតួនាទីជាតំណាងឱ្យសំឡេង និងផលប្រយោជន៍របស់ប្រជាពលរដ្ឋតាមឃុំ សង្កាត់នីមួយៗ គឺជាតួអង្គអភិបាលកិច្ចមូលដ្ឋានដ៏សំខាន់ក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការដ៏ថ្មីថ្មោងប្រកបដោយ ជោគជ័យក្នុងប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋបាលនៅកម្ពុជា។ ជោគជ័យនៃកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់ គឺជាបទពិសោធន៍ និងជាមូលដ្ឋានដ៏ចម្បងសម្រាប់រាជរដ្ឋាភិបាលកម្ពុជាពង្រីកកិច្ចដំណើរការកំណែទម្រង់នេះទៅថ្នាក់ក្រោមជាតិទាំងមូល ដែលគោលបំណងចុងក្រោយនៃកំណែទម្រង់នេះគឺ**ការអភិវឌ្ឍរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យក្លាយជាស្ថាប័នកាន់តែមានសមត្ថភាព និងលទ្ធភាពយ៉ាងពេញលេញក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្ដល់សេវាសាធារណៈចាំបាច់នានាឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋប្រកបដោយ គំនិតផ្ដួចផ្ដើម និងអាចមានភាពបត់បែនយ៉ាងរស់រវើកទៅតាមស្ថានភាពជាក់ស្ដែងនៅតាមមូលដ្ឋាននីមួយៗ**។នោះគឺជាការឆ្លុះបញ្ចាំងឱ្យឃើញពីការតាំងចិត្តរបស់រាជរដ្ឋាភិបាលក្នុងការសម្រេចចិត្តជ្រើសរើសយកគោលនយោបាយគ្រប់គ្រងរដ្ឋបាលមូលដ្ឋានតាមបែបប្រជាធិបតេយ្យ ដោយមានការចូលរួម ដែលកំពុងត្រូវបានអនុវត្តនៅក្នុងបណ្ដាប្រទេសជាច្រើនលើពិភពលោក បើទោះបីជានៅពេលនោះកម្ពុជាទើបនឹងចាកផុតពីសង្គ្រាមក៏ដោយ។

យើងទទួលស្គាល់ថា ការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជានៅមានភាពយឺតយ៉ាវ បើប្រៀបធៀបនឹងបណ្ដាប្រទេសមួយចំនួន។ ប៉ុន្តែយើងក៏ពុំអាចចម្លងយកនូវបែបផែនទាំងស្រុងនៃការអនុវត្តកំណែទម្រង់នេះរបស់បណ្ដាប្រទេសនានាដោយពុំបានគិតគូ ពិចារណាឱ្យបានច្បាស់លាស់អំពីស្ថានភាពជាក់ស្ដែងនៃនយោបាយ សេដ្ឋកិច្ច សង្គម វប្បធម៌ ប្រពៃណី និងប្រវត្តិសាស្ត្ររបស់យើងនោះដែរ។ ជាការពិតណាស់ ដើម្បីជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការដែលមានចរឹតជាកិច្ចការនយោបាយសាធារណៈដ៏សាំញ៉ាំមួយទៅរកផ្លូវដ៏ត្រឹមត្រូវល្អប្រសើរ ចាំបាច់ត្រូវការចំណាយពេលវេលាដ៏សមស្របមួយ ដោយហេតុថាកំណែទម្រង់នេះមិនមែនជាកិច្ច

ដំណើរការដែលតម្រូវឱ្យដើរត្រង់ទៅមុខដូចបន្ទាត់នោះទេ ប៉ុន្តែចាំបាច់ត្រូវអនុវត្តប្រកបដោយភាពបត់បែន និងជាបន្តបន្ទាប់ដែលគ្មានទីបញ្ចប់នោះឡើយ។

លើមូលដ្ឋាននេះក្នុងដំណើរការអនុវត្តគោលនយោបាយកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនារយៈពេលកន្លងមក យើងសម្រេចបាននូវសមិទ្ធផលគួរឱ្យកត់សម្គាល់ជាច្រើនពាក់ព័ន្ធទៅនឹងការរៀបចំលិខិតបទដ្ឋាន ការកែសម្រួលរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីនៃការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍សំខាន់ៗនៃអភិបាលកិច្ចតាមបែបប្រជាធិបតេយ្យដែលជាមូលដ្ឋានគ្រឹះដ៏សំខាន់ ដើម្បីបង្កលក្ខណៈឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិអាចបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនកាន់តែច្បាស់លាស់ និងកាន់តែច្រើនឡើងទាំងក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានាជូនប្រជាពលរដ្ឋ។

ជាមួយគ្នានឹងការពង្រឹងការគ្រប់គ្រងដឹកនាំរបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការរៀបចំឱ្យមានក្រុមប្រឹក្សាដែលកើតចេញពីការបោះឆ្នោតដោយផ្ទាល់ និងមិនផ្ទាល់តាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យ សេរី ពហុបក្សយន្តការនានាក៏ត្រូវបានបង្កើតឡើងដើម្បីបង្កលក្ខណៈឱ្យប្រជាពលរដ្ឋកាន់តែមានការយល់ដឹងអំពីសិទ្ធិ និងតួនាទីរបស់ខ្លួនក្នុងការចូលរួមផ្តល់យោបល់ដល់ការបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់នានារបស់ខ្លួនផងដែរ។

គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចជាច្រើនត្រូវបានផ្តួចផ្តើម និងកសាងឡើងដោយរដ្ឋបាលថ្នាក់ក្រោមជាតិតាមរយៈការប្រើប្រាស់កញ្ចប់មូលនិធិជាធន្ទានុសិទ្ធិរបស់ខ្លួនដែលបានផ្ទេរពីថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែច្រើនឡើងៗពីមួយឆ្នាំទៅមួយឆ្នាំ។តួនាទី និងសិទ្ធិអំណាចចាំបាច់មួយចំនួនក៏ត្រូវបានផ្ទេរទៅឱ្យថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រកាន់យកនូវការទទួលខុសត្រូវជាបណ្តើរៗក្នុងការផ្តល់ដោយផ្ទាល់នូវសេវាចាំបាច់ជាមូលដ្ឋានពាក់ព័ន្ធនឹងការលើកកម្ពស់គុណភាពនៃជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានរបស់ខ្លួន។

ទោះបីមានសមិទ្ធផលជាច្រើនដែលយើងសម្រេចបាន ប៉ុន្តែយើងក៏ជួបប្រទះនូវបញ្ហាប្រឈមមួយចំនួនដែលយើងបាន និងកំពុងពុះពារជម្នះដោះស្រាយដើម្បីបន្តជំរុញការអនុវត្តកំណែទម្រង់នេះផ្អែកតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជាពាក់ព័ន្ធទៅនឹងដំណើរការនៃការផ្ទេរមុខងារ និងធនធានដែលមានភាពយឺតយ៉ាវនៅឡើយ ហើយស្ថាប័ន និងធនធានមនុស្សនៃរដ្ឋបាលថ្នាក់ក្រោមជាតិក៏មានសមត្ថភាពនៅមានកម្រិត ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខេត្តដែលមានតួនាទីជាតំណាងរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលគាំទ្រដល់រដ្ឋបាលមូលដ្ឋានក្រុង ស្រុក និងឃុំក៏តម្រូវឱ្យមានការពិនិត្យ និងរៀបចំឡើងវិញឱ្យបានសមស្រប។ ក្នុងនោះរួមទាំងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធគ្រប់គ្រងរដ្ឋបាលសម្រាប់រដ្ឋបាលរាជធានីភ្នំពេញដែលជាទីក្រុងដ៏ធំ និងទីក្រុង ទីប្រជុំជននានាដែលកំពុងមានការកើនឡើងយ៉ាងឆាប់រហ័ស អាស្រ័យដោយកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម ការអភិវឌ្ឍ ហេដ្ឋារចនាសម្ព័ន្ធនានាជាច្រើន ដូចជាផ្លូវថ្នល់ ស្ពាន បណ្តាញអគ្គិសនី និងបណ្តាញផ្គត់ផ្គង់ទឹកស្អាតជាដើម។ ទន្ទឹមនឹងនេះ ក៏តម្រូវឱ្យមានការពិនិត្យ និងរៀបចំរចនាសម្ព័ន្ធ និងប្រព័ន្ធ

គ្រប់គ្រងរដ្ឋបាលមូលដ្ឋាន នៅតំបន់ជនបទដែលមានទំនាក់ទំនងផ្សារភ្ជាប់គ្នាជាប្រព័ន្ធរវាងទីក្រុង ទីប្រជុំជន និងតំបន់ជនបទ សំដៅចូលរួមជាមួយកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយគម្លាតរវាងទីក្រុង ទីប្រជុំជន និងតំបន់ជនបទ។ ក្រៅពីនេះ យើងក៏ជួបប្រទះនូវបញ្ហាប្រឈមនានាដែលពាក់ព័ន្ធទៅនឹងការប្រែប្រួលនៃចំនួនប្រជាជន ការប្រែប្រួលអាកាសធាតុ និងបញ្ហាដែលបានលេចចេញឡើងនៅក្នុងការអនុវត្តជាក់ស្តែងនូវរចនាសម្ព័ន្ធ និងប្រព័ន្ធនាពេលបច្ចុប្បន្នដែលតម្រូវឱ្យយើងត្រូវត្រួតពិនិត្យ និងកែលម្អឱ្យបានល្អប្រសើរឡើងបន្ថែមទៀត។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី**!

រយៈពេលបីឆ្នាំទៀតយើងនឹងឈានដល់ទីបញ្ចប់នៃកម្មវិធីជាតិរយៈពេល១០ឆ្នាំសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលគោលបំណងចុងក្រោយនៃកម្មវិធីជាតិនេះ **គឺការបង្កើតឡើងនូវរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានលទ្ធភាព និងសមត្ថភាពយ៉ាងពេញលេញក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាចាំបាច់នានាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព និងគុណភាព។** ហេតុដូច្នេះយើងពុំមានសេសសល់ពេលវេលាច្រើនទៀតទេបើប្រៀបធៀបទៅនឹងទំហំការងារដែលត្រូវដោះស្រាយដើម្បីសម្រេចបាននូវគោលបំណងប្រកបដោយលក្ខណៈមហិច្ឆតានៃកម្មវិធីជាតិនេះ។

លើមូលដ្ឋាននៃសមិទ្ធផល និងបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ ខ្ញុំសូមលើកឡើងអំពីការងារជាអាទិភាពនានាពាក់ព័ន្ធទៅនឹងទិសដៅនៃកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលតម្រូវឱ្យយើងទាំងអស់គ្នាខិតខំប្រឹងប្រែងអនុវត្តរួមគ្នាដូចខាងក្រោមនេះ៖

**ទីមួយ៖ ការបន្តលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការគ្រប់គ្រងកំណែទម្រង់**

ក្នុងនាមជាស្ថាប័នទទួលខុសត្រូវចំពោះរាជរដ្ឋាភិបាលក្នុងការដឹកនាំ និងសម្របសម្រួលកិច្ចដំណើរការកំណែទម្រង់នេះ គ.ជ.អ.ប.ត្រូវខិតខំបន្តលើកកម្ពស់ការគ្រប់គ្រង និងជំរុញកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការឱ្យបានកាន់តែស៊ីជម្រៅឈានឆ្ពោះទៅមុខប្រកបដោយនិរន្តរភាពនិងធ្វើឱ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ដើម្បីសម្រេចឱ្យបាននូវចក្ខុវិស័យ គោលដៅ និងគោលបំណងសំខាន់ៗនៃកម្មវិធីជាតិ។ផ្អែកលើសារៈសំខាន់ តម្រូវការចាំបាច់ និងការកើនឡើងនូវបន្ទុកការងារនៃកំណែទម្រង់ រាជរដ្ឋាភិបាលបានសម្រេចចិត្តផ្តល់ថវិកាប្រចាំឆ្នាំបន្ថែមទៀតសម្រាប់គាំទ្រដល់ គ.ជ.អ.ប ក្នុងការចំណាយទៅលើការគ្រប់គ្រងកំណែទម្រង់នេះដើម្បីធានានូវគុណតម្លៃនៃថវិការបស់រដ្ឋដែលបានវិនិយោគរាប់រយលានដុល្លារប្រចាំឆ្នាំទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ដោយឡែកក្រសួងស្ថាប័នពាក់ព័ន្ធនានា និងរដ្ឋបាលថ្នាក់ក្រោមជាតិក៏ចាំបាច់ត្រូវបន្តយកចិត្តទុកដាក់លើកកម្ពស់ភាពជាម្ចាស់របស់ស្ថាប័នខ្លួនក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដោយត្រូវចាត់ទុកការងារនេះថាជាកិច្ចការអាទិភាពរបស់ស្ថាប័នខ្លួន ហើយចាំបាច់ត្រូវរៀបចំជាផែនការសកម្មភាពឱ្យបានច្បាស់លាស់ និងប្រើប្រាស់ថវិការបស់ស្ថាប័ននីមួយៗដើម្បីអនុវត្តសកម្មភាពទាំងនេះផងដែរ។

**ទីពីរ៖ ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន**

ជាគោលការណ៍ការផ្ទេរមុខងារក្នុងក្របខ័ណ្ឌនៃគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការគឺ

ជាការផ្ទេរនូវការទទួលខុសត្រូវក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានដែលចាំបាច់មួយចំនួនពីក្រសួងស្ថាប័នទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនិងគណនេយ្យភាពនៃការផ្តល់សេវាទាំងនោះចំពោះប្រជាពលរដ្ឋ។

ផ្អែកតាមរបាយការណ៍បានបង្ហាញឱ្យឃើញថាការរៀបចំផ្ទេរមុខងាររបស់ក្រសួងស្ថាប័ននានានៅមានភាពប្រទាំងប្រទើសនិងមានល្បឿនមិនដូចគ្នានៅឡើយ។ជារួមរហូតមកដល់បច្ចុប្បន្ន មានមុខងារមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ក្រសួងតិចតួចណាស់ដែលខិតខំរៀបចំនិងសម្រេចចិត្តក្នុងការផ្ទេរមុខងារជាក់លាក់ជាបន្តបន្ទាប់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ដោយឡែកក្រសួងស្ថាប័នភាគច្រើននៅតែបន្តមានភាពអល់អែកស្ទាក់ស្ទើរក្នុងការសម្រេចចិត្តផ្ទេរមុខងារមួយចំនួនរបស់ស្ថាប័នខ្លួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនៅឡើយ។ជាទូទៅភាពស្ទាក់ស្ទើរទាំងនោះភាគច្រើនផ្តើមចេញពីការព្រួយបារម្ភខ្លាចបាត់បង់នូវសិទ្ធិអំណាចរបស់ខ្លួនជាជាងការបារម្ភទៅលើសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលនោះគឺជាកំហុសឆ្គងក្នុងទស្សនៈជាអ្នកដឹកនាំដែលយើងទាំងអស់គ្នាត្រូវតែបន្តពុះពារជម្នះ និងពង្រឹងការឯកភាពស្រុះស្រួលគ្នាជុំវិញការប្តេជ្ញាដោយឥតងាករេរបស់រាជរដ្ឋាភិបាលក្នុងកិច្ចដំណើរការកំណែទម្រង់នេះចាប់ពីដំណាក់កាលចាប់ផ្តើមរហូតដល់បច្ចុប្បន្ន និងតទៅអនាគត។

ជាការពិតណាស់ការផ្ទេរមុខងារចាំបាច់មួយចំនួនទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនឹងជួយកាត់បន្ថយនូវបន្ទុកការងាររបស់ក្រសួងស្ថាប័នលើកកម្ពស់គំនិតផ្តួចផ្តើមរបស់មូលដ្ឋានបង្កើនប្រសិទ្ធភាពនៃការរៀបចំគោលនយោបាយ និងការត្រួតពិនិត្យ ព្រមទាំងជំរុញឱ្យមានការធ្វើសេចក្តីសម្រេចចិត្តយ៉ាងឆាប់រហ័សក្នុងការអភិវឌ្ឍមូលដ្ឋាននិងការផ្តល់សេវានានាដែលជាតម្រូវការដ៏ចាំបាច់បំផុតរបស់ប្រជាពលរដ្ឋ។

ក្នុងន័យនេះខ្ញុំសូមជំរុញលើកទឹកចិត្ត និងណែនាំជាថ្មីម្តងទៀតដល់ក្រសួងស្ថាប័នពាក់ព័ន្ធនឹងវិស័យនានាត្រូវខិតខំជំរុញការផ្ទេរមុខងារដែលមានលក្ខណៈសមស្របនិងជាក់លាក់ក្នុងវិស័យនីមួយៗទាំងក្នុងបែបផែននៃការផ្ទេរជាការប្រគល់និងជាការធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។បន្ទាប់ពីមានការសម្រេចចិត្តក្នុងការផ្ទេរមុខងារណាមួយរួចហើយក្រសួងស្ថាប័ននោះក៏ត្រូវបន្តជួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពផ្នែកបច្ចេកទេសឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីធានាថារដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានសមត្ថភាព និងលទ្ធភាពក្នុងការអនុវត្តនូវមុខងារនោះឱ្យបានពេញលេញនិងមានប្រសិទ្ធភាព។នៅក្នុងកិច្ចដំណើរការផ្ទេរមុខងារនេះចាំបាច់ត្រូវចៀសវាងឱ្យបាននូវការផ្ទេរមុខងារទាំងឡាយណាដែលពុំមានការផ្ទេរឬការកំណត់នូវធនធានហិរញ្ញវត្ថុចាំបាច់នានាសម្រាប់ចាត់ចែងប្រើប្រាស់ក្នុងការអនុវត្តមុខងារទាំងនោះ។

ក្រសួងមហាផ្ទៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈត្រូវខិតខំសហការគ្នាដើម្បីបន្តរៀបចំនិងដាក់ចេញនូវប្រព័ន្ធនិងយន្តការនានាដែលធានាដល់ការផ្ទេរធនធាននានាទាំងធនធានមនុស្សនិងធនធានហិរញ្ញវត្ថុភ្ជាប់ទៅជាមួយមុខងារទាំងនោះផងដែរ។

ទន្ទឹមនឹងនេះ ការសិក្សានិងការវិភាគអំពីលទ្ធភាពនៃការធ្វើសមាហរណកម្មការិយាល័យ

ជំនាញនានានៅថ្នាក់ក្រុងស្រុកទៅក្នុងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលក្រុងស្រុកគប្បីត្រូវបានបញ្ចប់ឱ្យបានឆាប់ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការធ្វើសេចក្តីសម្រេចចិត្តរបស់រាជរដ្ឋាភិបាលដែលខ្ញុំគិតថានេះជាកិច្ចការដ៏មានសារៈសំខាន់មួយទៀតក្នុងការពន្លឿនកិច្ចដំណើរការផ្ទេរមុខងារនិងការពង្រឹងតួនាទីនិងការទទួលខុសត្រូវរបស់រដ្ឋបាលក្រុងស្រុកដើម្បីសហការជាមួយនឹងរដ្ឋបាលឃុំ សង្កាត់ក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន។

ដោយឡែកយន្តការផ្តល់សេវារដ្ឋបាលចាំបាច់នានាជូនប្រជាពលរដ្ឋតាមការិយាល័យច្រកចេញចូលតែមួយនៅក្រុងស្រុកមួយចំនួនដែលកំពុងបង្កភាពងាយស្រួលនិងទទួលបានការពេញចិត្តពីប្រជាពលរដ្ឋក៏ចាំបាច់ត្រូវបន្តពង្រឹងនិងពង្រីកឱ្យបានទូលំទូលាយនៅគ្រប់រដ្ឋបាលថ្នាក់ក្រោមជាតិទូទាំងប្រទេសឱ្យបានឆាប់រហ័សផងដែរ។ផ្អែកតាមស្មារតីនៃអនុក្រឹត្យលេខ១៨អនក្រ.បកចុះថ្ងៃទី០៨ខែកុម្ភៈឆ្នាំ២០១៧ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិក្រសួងស្ថាប័នពាក់ព័ន្ធនានាចាំបាច់ត្រូវបន្តគាំទ្រនិងផ្ទេរមុខងារថ្មីៗបន្ថែមទៀតទៅឱ្យយន្តការនេះ។

**ទីបី៖ ការអភិវឌ្ឍស្ថាប័នរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំសូមគូសបញ្ជាក់ថា ការអភិវឌ្ឍស្ថាប័ននៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចំនួន៣ថ្នាក់ក្នុងក្របខ័ណ្ឌនៃគោលនយោបាយវិមជ្ឈការចាំបាច់ត្រូវធានាឱ្យបាននូវគោលការណ៍មួយចំនួន ពោលគឺ៖

១. ការពង្រឹងនូវទំនាក់ទំនងជាប្រក្រតី និងមានលក្ខណៈជាប្រព័ន្ធរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

២. ការបន្តពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការគាំទ្រគ្នាទៅវិញទៅមករវាងរដ្ឋបាលនានានៅថ្នាក់ក្រោមជាតិ
ដោយគោរពនូវស្វ័យភាពនៃនីតិបុគ្គលសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ

៣. ការពង្រឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិតាមគោលការណ៍រដ្ឋបាលឯកភាព
ដើម្បីធានាដល់ការសម្របសម្រួលគ្នារវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួងស្ថាប័ននានា។

ជាមួយគ្នានេះដែរ ការកំណត់បែងចែកឱ្យបានច្បាស់លាស់ពីចរឹតលក្ខណៈ និងប្រភេទផ្សេងៗគ្នា ផ្អែកលើវិសាលភាព និងភាពជាតំណាងរបស់ថ្នាក់នីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិគឺជាមូលដ្ឋានដ៏សំខាន់នៅក្នុងការរៀបចំផែនការអភិវឌ្ឍស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិទៅអនាគត។ខេត្តគប្បីរៀបចំក្នុងទម្រង់ជារដ្ឋបាលតំបន់ដែលមានតួនាទីតំណាងឱ្យថ្នាក់ជាតិក្នុងការគាំទ្រ ការសម្របសម្រួល និងការត្រួតពិនិត្យការអនុវត្តរបស់រដ្ឋបាលមូលដ្ឋានដែលមានទាំងតំបន់ទីក្រុង ទីប្រជុំជន និងតំបន់ជនបទ ក្នុងដែនដីនៃខេត្តនីមួយៗ។ ស្របពេលជាមួយគ្នានេះ រដ្ឋបាលខេត្តក៏ត្រូវបានប្រគល់មុខងារក្នុងការអភិវឌ្ឍគម្រោងធំៗមួយចំនួនដែលថ្នាក់ជាតិប្រគល់ឱ្យ ក៏ប៉ុន្តែក៏ចាំបាច់ត្រូវមានការគិតគូររៀបចំនូវប្រព័ន្ធគ្រប់គ្រងរដ្ឋបាលដោយឡែកៗ សម្រាប់តំបន់ដែលជាទីប្រជុំជនកុះករ និងតំបន់ដែលត្រូវជំរុញឱ្យក្លាយជាតំបន់សេដ្ឋកិច្ចពិសេសធំៗផងដែរ ឧទាហរណ៍ដូចជារាជធានីភ្នំពេញ និងខេត្ត

ព្រះសីហនុជាដើម។ ដោយឡែក ក្រុងស្រុក និងឃុំសង្កាត់ចាំបាច់ត្រូវបានពង្រឹងឱ្យក្លាយជារដ្ឋបាលមូលដ្ឋានដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍមូលដ្ឋាន និងផ្តល់សេវាសាធារណៈចាំបាច់ និងសមស្របដោយផ្ទាល់ជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួននីមួយៗ។

ក្នុងន័យនេះ ក្រសួងមហាផ្ទៃត្រូវទទួលខុសត្រូវ ដោយមានកិច្ចសហការយ៉ាងជិតស្និទជាមួយក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងផែនការដើម្បីរៀបចំឱ្យមានការសិក្សា និងវិភាគឱ្យបានច្បាស់លាស់អំពីបែបផែននៃការគ្រប់គ្រងរដ្ឋបាលទៅតាមចរឹតលក្ខណៈ និងប្រភេទផ្សេងៗគ្នានេះ ដើម្បីធានាដល់ការរៀបចំផែនការអភិវឌ្ឍស្ថាប័ន និងការវិភាជធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិតាមប្រភេទនីមួយៗឱ្យបានសមស្រប ដើម្បីធានាដល់ការលើកកម្ពស់ប្រសិទ្ធភាព និងនិរន្តរភាពនៃការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។

**ទីបួន៖ ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ**

ដើម្បីធានាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិកាន់តែមានលទ្ធភាពសម្រេចបាននូវតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនក្នុងការដោះស្រាយនូវបញ្ហាប្រឈមនានាទៅអនាគត យើងចាំបាច់ត្រូវខិតខំបន្តពង្រឹងនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយផ្អែកលើគោលការណ៍សំខាន់ចំនួន៣ ពោលគឺ ការគ្រប់គ្រង និងបែងចែកការទទួលខុសត្រូវយ៉ាងច្បាស់លាស់ក្នុងការចំណាយ ការបង្កើតឱ្យមានចំណូលរបស់មូលដ្ឋាន និងការបន្តពង្រឹងប្រព័ន្ធផ្ទេរធនធានអន្តររដ្ឋបាល។

ក្នុងឆ្នាំ២០១៨នេះ រដ្ឋនឹងផ្ទេរថវិកាប្រមាណជាង៤៣០លានដុល្លារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិទាំង៣ថ្នាក់ដើម្បីចាត់ចែងប្រើប្រាស់ដោយឆន្ទានុសិទ្ធិសម្រាប់ការចំណាយទៅលើការងាររដ្ឋបាលទូទៅ និងការអនុវត្តនូវគម្រោងអភិវឌ្ឍមូលដ្ឋាននានា។ ជាមួយគ្នានេះ ថវិការាប់រយលានដុល្លារទៀតក៏ត្រូវបានផ្ទេរពីក្រសួង ស្ថាប័នវិស័យនានាទៅឱ្យមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ខ្លួននៅរាជធានី ខេត្ត និងក្រុងស្រុកដើម្បីអនុវត្តនូវមុខងារក្នុងវិស័យនីមួយៗនៅតាមមូលដ្ឋាន ដែលក្នុងនោះរួមមានថវិកាមួយចំនួនកំពុងត្រូវបានរៀបចំផ្ទេរត្រង់ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ សម្រាប់ចាត់ចែងប្រើប្រាស់ក្នុងការអនុវត្តមុខងារដែលក្រសួងស្ថាប័នមួយចំនួនបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិរួចហើយ។ ក្រៅពីនេះ យន្តការមួយចំនួនទៀតក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវមូលនិធិសម្រាប់គម្រោងវិនិយោគចាំបាច់មួយចំនួនរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ដើម្បីសម្រេចបាននូវសំណូមពរនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបន្តយកចិត្តទុកដាក់លើកិច្ចការមួយចំនួនដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃប្រព័ន្ធផ្ទេរធនធានអន្តររដ្ឋបាល ពោលគឺ៖

១. ការធានាឱ្យបាននូវយន្តការផ្ទេរធនធានដែលអាចព្យាករណ៍បាន ប្រកបដោយភាពទៀងទាត់ និងមានតម្លាភាព

២.ការពង្រីក និងពង្រឹងការប្រើប្រាស់ប្រព័ន្ធផ្ទេរធនធានប្រកបដោយសមធម៌ដោយផ្អែកលើរូបមន្តមួយដែលអាចវាស់វែងបានពីតម្រូវការនៃការចំណាយ ផ្អែកលើសមត្ថភាពនៃការប្រមូលចំណូល និងការដាក់ចេញនូវវិធានដោយឡែកមួយសម្រាប់ការប្រមូលមូលនិធិជាកញ្ចប់រួមដើម្បីបែងចែកទៅវិញប្រកបដោយសមធម៌រវាងតំបន់ដែលមានធនធាន និងតំបន់

ក្រីក្រ

៣. ការបន្តពង្រឹងយន្តការផ្ទេរធនធានមានភ្ជាប់ល័ក្ខខ័ណ្ឌដើម្បីធានាដល់ការអនុវត្តនូវមុខងារដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និង

៤. ការរៀបចំ និងដាក់ឲ្យអនុវត្តនូវយន្តការនៃការផ្តល់ធនធានផ្អែកលើលទ្ធផលនៃការបំពេញមុខងារ ដើម្បីលើកទឹកចិត្តដល់ការគ្រប់គ្រងថវិកា និងការលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវា។

រាជរដ្ឋាភិបាលបានប្តេជ្ញាចិត្តក្នុងការបង្កើនការផ្តល់ធនធានជារៀងរាល់ឆ្នាំទៅឱ្យមូលនិធិឃុំសង្កាត់ និងក្រុងស្រុក ចាប់ពីឆ្នាំ២០១៩តទៅ។អាស្រ័យហេតុនេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវគិតគូររៀបចំគម្រោងបង្កើនការវិភាជធនធានរដ្ឋទៅឱ្យមូលនិធិទាំងពីរថ្នាក់នេះឱ្យបានសមស្រប និងត្រូវយកចិត្តទុកដាក់បន្តការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានលទ្ធភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុប្រកបដោយប្រសិទ្ធភាព តម្លាភាព និងសុចរិតភាពផងដែរ។

ខាងលើនេះគឺជាបញ្ហាជាគន្លឹះមួយចំនួន ដែលខ្ញុំសូមផ្តល់ជាអនុសាសន៍បន្ថែមទៅលើទិសដៅនៃកំណែទម្រង់វិមជ្ឈការ និងសហវិមជ្ឈការដែល គ.ជ.អ.ប បានដាក់ចេញសម្រាប់រយៈពេល៣ឆ្នាំខាងមុខ។ក្រៅពីនេះ ក៏រួមមាននូវបញ្ហាសំខាន់ៗមួយចំនួនទៀតដែលតម្រូវឱ្យយើងខិតខំបន្តដោះស្រាយនៅក្នុងកិច្ចដំណើរការជាទូទៅនៃកំណែទម្រង់នេះ ដែលក្នុងនោះរួមមាន ការពង្រឹងប្រព័ន្ធគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្ស ការលើកកម្ពស់បរិយាប័ន្ននិងសមធម៌សង្គម និងការពង្រឹងភាពជាដៃគូជាមួយវិស័យឯកជន អង្គការសង្គមស៊ីវិល និងសហគមន៍មូលដ្ឋាននៅក្នុងការអភិវឌ្ឍមូលដ្ឋាន និងការផ្តល់សេវាសាធារណៈនានា។ ក្នុងចំណុចនេះ ខ្ញុំសូមគូសបញ្ជាក់ឡើងវិញអំពីភាពចាំបាច់របស់រាជរដ្ឋាភិបាលក្នុងការ បំពេញការងារដោយមានការចូលរួមប្រកបដោយភាពជាដៃគូដ៏ស្មោះស ជាមួយអង្គការសង្គមស៊ីវិលទាំងអង្គការក្នុងស្រុក និងអង្គការអន្តរជាតិនានាដោយឈរលើគោលការណ៍នីតិរដ្ឋនៅក្នុងដំណើរការ កំណែទម្រង់នេះ និងកិច្ចការនានារបស់រាជរដ្ឋាភិបាល។

ជាមួយគ្នានេះដែរ រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបន្តខិតខំកែប្រែទម្លាប់ និងឥរិយាបថនៃការគ្រប់គ្រង និងការចាត់ចែងការងារនៅគ្រប់ថ្នាក់ និងលើកកម្ពស់ការបំពេញតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ផ្អែកតាមរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីបំពេញការងារដែលបានកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដោយខិតខំផ្តួចផ្តើមគំនិតដោះស្រាយបញ្ហាជាអាទិភាពនានារបស់មូលដ្ឋាន និងការផ្តល់សេវាតាមរយៈមុខងារជាអាណត្តិទូទៅរបស់ខ្លួន និងមុខងារជាកាតព្វកិច្ចដែលថ្នាក់ជាតិបានផ្ទេរឱ្យ។ ទន្ទឹមនេះ ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងកិច្ចប្រតិបត្តិការរបស់ខ្លួន រដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ចាំបាច់ត្រូវធានាឱ្យមានការចូលរួមផ្តល់មតិ និងការស្តាប់យោបល់របស់ប្រជាពលរដ្ឋ ព្រមទាំងដាក់ចេញនូវវិធានការឱ្យបានច្បាស់លាស់ក្នុងការលើកកម្ពស់សីលធម៌ និងឥរិយាបថរបស់មន្ត្រីឱ្យខិតខំបំពេញការងាររបស់ខ្លួនក្នុងនាមជាអ្នកបម្រើផលប្រយោជន៍របស់ប្រជាពលរដ្ឋយ៉ាងពិតប្រាកដ។

ក្នុងនាមជាអ្នកនយោបាយនៅមូលដ្ឋាន ក្រុមប្រឹក្សានៅគ្រប់ថ្នាក់ និងមន្ត្រីរាជការនានាដែលបម្រើការងារនៅតាមថ្នាក់រដ្ឋបាលនីមួយៗនៅថ្នាក់ក្រោមជាតិត្រូវបន្តខិតខំប្រឹងប្រែងលើកម្ពស់ជាប្រចាំក្នុងការប្រាស្រ័យទាក់ទងដោយផ្ទាល់ជាមួយប្រជាពលរដ្ឋគ្រប់និន្នាការនយោបាយ និងគ្រប់មជ្ឈដ្ឋាននៅតាមមូលដ្ឋានរបស់ខ្លួន ដើម្បីលើកទឹកចិត្តឱ្យមានការចូលរួមគ្រប់កិច្ចការនៅមូលដ្ឋាន និងត្រូវខិតខំស្វែងយល់អំពីតម្រូវការ សំណើសំណូមពរនិងទុក្ខកង្វល់នានារបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន សំដៅប្រឹងប្រែងឆ្លើយតបនូវសំណើសំណូមពរ ទុក្ខកង្វល់ទាំងនោះដើម្បីបង្កើននូវជំនឿជឿជាក់ និងទំនុកចិត្តពីប្រជាពលរដ្ឋ។

**សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី**!

ភាពជោគជ័យនៃការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនឹងផ្តល់នូវកាលានុវត្តភាពដ៏ល្អប្រសើរដើម្បីបន្តសម្រេចបាននូវការរីកចម្រើនប្រកបដោយសមធម៌និងសម្រេចបាននូវការអភិវឌ្ឍមូលដ្ឋានប្រកបដោយនីរន្តរភាព សំដៅចូលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការឈានទៅកាត់បន្ថយភាពក្រីក្រឱ្យកាន់តែឆាប់រហ័សថែមទៀតនារយៈពេលដ៏ខ្លីខាងមុខនេះ។ នេះជាបំណងប្រាថ្នារបស់យើង ដើម្បីធ្វើឱ្យគុណភាពនៃជីវិតរបស់ប្រជាពលរដ្ឋកម្ពុជាគ្រប់រូបកាន់តែល្អប្រសើរឡើង។ ក្នុងនាមរាជរដ្ឋាភិបាល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានសេចក្តីសង្ឃឹមយ៉ាងមុតមាំថាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ក្រសួងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងឡាយនឹងបន្តខិតខំប្រឹងប្រែងរួមគ្នាដើម្បីអនុវត្តឱ្យបានសម្រេចដោយជោគជ័យនូវចក្ខុវិស័យ គោលដៅ និងគោលបំណងនៃកម្មវិធីកំណែទម្រង់នេះ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមប្រកបដោយពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងសូមប្រកាសបិទសន្និសីទជាតិស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅពេលនេះ។

***សូមអរគុណ***!